គម្រោងការលើកកម្ពស់ជីវភាពធន់នឹងអាកាសធាតុនៃសហគមន៍ផលិតស្រូវនៅតំបន់ទន្លេសាប (PCRL)

រាជរដ្ឋាភិបាលកម្ពុជា បានទទួលហិរញ្ញប្បទានឥតសំណងពីមូលនិធិបរិស្ថានសកល (GEF) តាមរយៈអង្គការស្បៀង និងកសិកម្មនៃសហប្រជាជាតិ (FAO) សម្រាប់អនុវត្តគម្រោងដែលមានរយៈពេលប្រាំឆ្នាំ (២០២២-២០២៧) ដែលមានគោលបំណងកាត់បន្ថយភាពងាយរងគ្រោះដោយសារអាកាសធាតុ និងបង្កើនភាពធន់ទៅនឹងការប្រែប្រួលអាកាសធាតុរបស់ប្រជាសហគមន៍ដាំស្រូវ តាមរយៈការអនុវត្តវិធីសាស្ត្រផលិតកម្មផ្អែកលើប្រព័ន្ធអេកូឡូស៊ី និងជំរុញចរន្តទីផ្សារ។ គម្រោង PCRL នេះ សហការអនុវត្តដោយអគ្គនាយកដ្ឋានកសិកម្ម (GDA) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន (GDLC) នៃក្រសួងបរិស្ថាន។



តំបន់គោលដៅ

គម្រោង PCRL អនុវត្តក្នុងខេត្តគោលដៅចំនួនប្រាំនៅជុំវិញបឹងទន្លេសាប ពោលគឺខេត្តពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ សៀមរាប និងកំពង់ធំ ដោយគ្របដណ្តប់សរុបចំនួន ៤៨ ឃុំ ក្នុង ៣២ ស្រុក ដែលជាតំបន់ដាំដុះស្រូវដ៏សំខាន់ ដែលមានភ្លៀងធ្លាក់ច្រើន ប៉ុន្តែលទ្ធភាពប្រើប្រាស់ប្រព័ន្ធធារាសាស្ត្រនៅមានកម្រិត និងជាទីដែលសហគមន៍ងាយរងគ្រោះភាគច្រើន មានលទ្ធភាពបន្សុាំតិចតួចទៅនឹងការប្រែប្រួលអាកាសធាតុ។

សមាសភាគគម្រោង

សមាសភាគទី ១៖ ការកែលម្អបរិយាកាសអំណោយផលសម្រាប់ការបន្សុាំនឹងការប្រែប្រួលអាកាសធាតុនៅក្នុងវិស័យស្រូវអង្ករ និងវិស័យអាទិភាពពាក់ព័ន្ធ តាមរយៈការធ្វើគោលនយោបាយ និងផែនការរួមគ្នា។

លទ្ធផលរូបវន្ត ១.១៖ គោលនយោបាយបន្សុាំនឹងការប្រែប្រួលអាកាសធាតុនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងក្របខ័ណ្ឌផែនការ និងអភិបាលកិច្ច ទទួលបានការពង្រឹងអោយកាន់តែរឹងមាំ។

សមាសភាគទី ២៖ ការគាំទ្រប្រព័ន្ធផលិតកម្មធន់នឹងអាកាសធាតុនៅតាមសហគមន៍ផលិតស្រូវ ដើម្បីឱ្យជីវភាពរស់នៅបានប្រសើរឡើង។

លទ្ធផលរូបវន្ត ២.១៖ សមត្ថភាពបន្សុាំនឹងការប្រែប្រួលអាកាសធាតុនៃប្រព័ន្ធផលិតកម្ម និងធនធានធម្មជាតិនៅមូលដ្ឋាន មានភាពធន់កាន់តែប្រសើរ។

សមាសភាគទី ៣៖ ការពង្រឹងវិសាលភាពបច្ចេកវិទ្យាបន្សុាំ និងការអនុវត្តនៅក្នុងខ្សែច្រវាក់តម្លៃដែលបានជ្រើសរើស តាមរយៈភាពជាដៃគូរទីផ្សារ និងការវិនិយោគ។

លទ្ធផលរូបវន្ត ៣.១៖ ការពង្រឹងវិសាលភាពនៃការចំណាយប្រឌិតថ្មីក្នុងការបន្សុាំ បច្ចេកវិទ្យា និងទីផ្សារថ្មីៗ ព្រមទាំងការពង្រីកអាជីវកម្មកសិកម្ម ឱកាសការងារ និងការពង្រឹងសិទ្ធិអំណាចនៅកម្រិតសហគមន៍។

សមាសភាគទី ៤៖ ការកសាងការគ្រប់គ្រងចំណេះដឹង នវានុវត្តន៍ និងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃប្រកបដោយប្រសិទ្ធភាព។

លទ្ធផលរូបវន្ត ៤.១៖ ការគ្រប់គ្រងចំណេះដឹង និងការវាយតម្លៃនវានុវត្តន៍នានាក្នុងការបន្សុាំនឹងការប្រែប្រួលអាកាសធាតុ កាន់តែមានប្រសិទ្ធិភាពឡើង។

លទ្ធផលរំពឹងទុក

- បង្កើនភាពធន់ និងសមត្ថភាពបន្សុាំដល់កសិករចំនួន ១៧០,២០០ នាក់
- ផ្ទៃដីកសិកម្មធន់នឹងអាកាសធាតុ ៦៧,៣០៩ ហិកតា
- ថែរក្សា ឬកែលម្អសេវាប្រព័ន្ធអេកូឡូស៊ី
- ការអភិវឌ្ឍន៍ដែលធន់នឹងអាកាសធាតុ នៅតាមសហគមន៍ដាំស្រូវនៅជុំវិញបឹងទន្លេសាប។

លទ្ធផលរយៈពេលវែង

- ផលិតភាព និងគុណភាពនៃផលិតផលកសិកម្មរបស់អ្នកប្រកបរបរតូចតាច ត្រូវបានបង្កើនឡើង។
- សន្តិសុខស្បៀង ភាពធន់នៃនឹងសេដ្ឋកិច្ចគ្រួសារ មានប្រាក់ចំណូល និងអាហារូបត្ថម្ភល្អប្រសើរ។
- ការសឹករវាលដី និងការបញ្ចេញឧស្ម័នផ្ទះកញ្ចក់ ត្រូវបានកាត់បន្ថយ ចំណែកជីវចម្រុះ និងប្រព័ន្ធអេកូឡូស៊ីមានលំនឹងល្អប្រសើរ។

ទំនាក់ទំនង៖
យស់ ភារម៉ា អ្នកជំនាញប្រចាំផ្នែកទំនាក់ទំនងការងារ PCRL
អគ្គនាយកដ្ឋានកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អាសយដ្ឋាន៖ #54B/49F, ផ្លូវ 395-656, សង្កាត់ទឹកល្អក់ពី, ខណ្ឌទួលគោក, ភ្នំពេញ
អ៊ីម៉ែល៖ info@pcrl.org
ទូរស័ព្ទ៖ 077 878 001
ហ្វេសប៊ុក៖ pcrlproject
គេហទំព័រ៖ www.pcrl.org

ទាញយកពីគេហទំព័រ៖ Food and Agriculture Organization of the United Nations
សហការគ្នាដោយ៖
ថវិកាបានមកពីៈ gef